ប្រមេះ និង រលាករន្ធនោម ឬ រន្ធយោនី (chlamydia) គឺជាកាមរោគ (STDs) ដែលអាចឆ្លងបានតាមការសេពមេថុនជាមួយអ្នកដទៃដោយគ្មានប្រដាប់ការពារ (លិង្គទៅក្នុងយោនី ប្រើមាត់ទៅលើលិង្គ ប្រើមាត់ទៅលើយោនី លិង្គទៅក្នុងគូទ ការធ្វើឲ្យមានសម្រើប)។ រោគទាំងពីរប្រភេទនេះឧស្សាហ៍កើតមានណាស់ នៅក្នុងចំណោមយុវវ័យនៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

ជាទូទៅរោគ ប្រមេះ និង រលាករន្ធនោម ឬ រន្ធយោនី នេះ**<u>គ្មានបង្ហាញរោគសញ្ញា</u>**អ្វីទេ វិធីតែមួយគត់ដែលអាចដឹងថាអ្នកមានរោគនេះឬអត់ គឺតាមរយៈការធ្វើពិសោធន៍។

ការធ្វើពិសោធគឺ**<u>លាក់ការសម្ងាត់</u>**។ យើងគោរពតាមច្បាប់របស់ HIPPA ហេតុនេះយើងមិនអាចប្រាប់ព័ត៌មានអ្វីមួយរបស់អ្នកទៅ ក្រុមគ្រួសារ គ្រូ មិត្តប្រុស/មិត្តស្រី របស់អ្នកឲ្យដឹងនោះទេ។

ការពិសោធន៍គឺ**<u>ស្រេចតាមចិត្តរបស់បុគ្គល</u>**។ អ្នកមិនបាច់បត់ជើងតូចដាក់ក្នុងកំប៉ុងនោះទេ ប៉ុន្តែអ្នកត្រូវតែបំពេញព័ត៌មាននៅលើក្រដាសស ហើយដើរចូលបន្ទប់ទឹក។

## វិធីធ្វើពិសោធន៍



១. សិស្សម្នាក់ៗទទួលកញ្ចប់ពណ៌ត្នោតមួយ។

២. សិស្សម្នាក់ៗបំពេញក្រដាសស។

៣. សិស្សម្នាក់ៗដាក់ក្រដាសសនៅក្នុងកញ្ចប់ពណ៌ត្នោត។

៤. **សិស្សម្នាក់ៗចូលទៅក្នុងបន្ទប់ទឹក។**

៥. **<u>បើសិនជាអ្នកចង់ឲ្យគេធ្វើពិសោធន៍៖</u>**
បត់ជើងតូចដាក់កំប៉ុង មួលបិទគម្រប ដាក់កំប៉ុងនៅក្នុងកញ្ចប់ពណ៌ត្នោតជាមួយក្រដាសស។

៦. យើងនឹងប្រមូលយកកញ្ចប់ពណ៌ត្នោតទាំងអស់នៅពេលអ្នកចេញមកពីបន្ទប់ទឹក។

៧. លទ្ធផលនៃការពិសោធន៍នឹងដឹងក្នុងរយៈពេលពីរសប្តាហ៍។

# បើអ្នកធ្លាប់សេពមេថុន អ្នកគប្បីធ្វើការពិសោធន៍នៅថ្ងៃនេះ